# ក្មេងដែលប្រើទូរស័ព្ទដៃពុំសូវមានសុវត្ថភាពក្នុងការដើរឆ្លងកាត់ថ្នល់នោះឡើយ

Kids With Cell Phones Not as Safe Crossing Streets
WUML
4/13/08

ក្មេងដែលកំពុងដើរកាត់ថ្នល់ ហើយនិយាយទូរស័ព្ទដៃប្រហែលជាអាចមានគ្រោះថ្នាក់បាន។

ការសិក្សានេះបានត្រូវលើកយកទៅពិភាក្សានៅក្នុងទីសន្និបាតជាតិមួយ នៅទីក្រុង Miami កាលពីថ្ងៃសុក្រទី 11 ខែមេសាកន្លងមកនេះ ស្តីអំពីសុខភាពផ្លូវចិត្តរបស់ក្មេងៗ។ អ្នកធ្វើការសិក្សានៅសាកលវិទ្យាល័យ Miami បានរកឃើញថា ក្មេងដែលមានអារម្មណ៍ពុំមូល នៅពេលដើរឆ្លងថ្នល់ អាចទទួលគ្រោះថ្នាក់ដោយមានរថយន្តបុក ឬក៏ដោយការធ្វេសប្រហែសផ្សេងៗ បាន។

អ្នកស្រី Katherine Byington និសិត្សបណ្ឌិតចិត្តសាស្ត្រ នៅសាកលវិទ្យាល័យ Alabama នៅទីក្រុង Birmingham មានប្រសាសន៍ក្នុងសន្និបាតនេះថា ជាការមួយសំខាន់ណាស់ ដែលក្មេងៗ ក៏ដូចជាអ្នកបើកបរ គួរដឹងនិងជ្រាបអំពីសារៈសំខាន់ នៃគ្រោះថ្នាក់ក្នុងការនិយាយទូរស័ព្ទនៅពេលឆ្លងកាត់ថ្នល់។

យោលទៅតាមលទ្ធផលនៃកាសិក្សាមួយ នៅសាកលវិទ្យាល័យ Alabama នៅទីក្រុង Birmingham បានឲ្យដឹងថា មានក្មេងអាយុ ពី 10 ឆ្នាំ ទៅ 12 ឆ្នាំ ចំនួន 1/3 ដែលប្រើទូរស័ព្ទដៃ។

តាមសេចក្តីរាយការណ៍នេះ សូម្បីតែការដើរឆ្លងកាត់ថ្នលប៉ុណ្ណោះ ក៏ត្រូវការប្រើខួរក្បាលយ៉ាងមមាញឹកដែរ ហើយគ្រោះថ្នាក់របួស ដោយសារការធ្វេសប្រហែស នៅពេលឆ្លងថ្នល់ ជាកត្តាចំបងបង្អស់ ដែលបណ្តាលឲ្យក្មេងរៀននៅសាលាអនុវិទ្យាល័យស្លាប់បាត់បង់ជីវិត។

ជាមួយគ្នានេះ មានក្មេងកាន់តែមានអាយុតិចទៅៗ ដែលមានទូរស័ព្ទដៃ។ អ្នកស្រី Byington បន្ថែមថា ក្រុមហ៊ុនលក់ទូរស័ព្ទមានទេពកោសលក្នុងការផ្សាយលក់ដើម្បីទាក់ទាញអារម្មណ៍ក្មេងៗ។ ហើយម្យ៉ាងទៀតក្មេងពុំទាន់ចេះបើករថយន្តបាន ទៅសាលារៀន ឬទៅផ្ទះមិត្រភ័ក្តពុំដឹងថា ការបើករថយន្តត្រូវប្រយ័ត្ន មើលឃើញយ៉ាងដូចម្តេច។ នេះប្រហែល ជាមូលហេតុដែលបណ្តាលឲ្យក្មេងមានគ្រោះថ្នាក់ នៅពេលឆ្លងថ្នល់។

តាមការស្រាវជ្រាវមួយ បានប៉ាន់ស្មានថា ទំរាំដល់ឆ្នាំ 2009 ក្មេងអាយុពី 8 ឆ្នាំ ទៅ 12 ឆ្នាំ ចំនួន 54% នឹងមានទូរស័ព្ទដៃប្រើ គឺ ពីរដង លើសពីចំនួនដែលមាននៅក្នុងឆ្នាំ 2006។ អ្នកស្រីបានធ្វើការពិសោធន៍ជាមួយក្មេងចំនួន 77 នាក់ ដែលមានអាយុពី 10 ឆ្នាំ ទៅទល់នឹង 12ឆ្នាំ។ លទ្ធផលនៃការពិសោធន៍នេះ បានឲ្យដឹងថា ក្មេងដែលនិយាយទូរស័ព្ទដៃ នៅពេលខ្លួនកំពុងដើរឆ្លងកាត់ថ្នល់ អាចមានគ្រោះថ្នាក់ដោយត្រូវរថយន្តបុក ជាងក្មេងដែលពុំនិយាយទូរស័ព្ទ នៅពេលនោះ។

វេជ្ជបណ្ឌិត Judy Schaechter សាស្ត្រាចារ្យរងផ្នែកវិជ្ជាពេទ្យកុមារ នៅសាកលវិទ្យាល័យ Miami សាលាពេទ្យ  Miller, University of Miami, Miller School of Medicine មានប្រសាសន៍ថា មាតាបិតាគួរជ្រាបអំពីបញ្ហាគ្រោះថ្នាក់នេះ ឲ្យមែនទែន មុនពេលសំរេចចិត្ត ទិញទូរស័ព្ទឲ្យកូន ហើយមាតាបិតាគួរ និយាយបញ្ជាក់ អំពីវិន័យក្នុងការប្រើទូរស័ព្ទដៃ ឲ្យបានច្បាស់លាស់ និងផលវិបាក ដែលក្មេងត្រូវទទួល នៅពេលពុំអនុវត្តតាមវិន័យទាំងនោះ។ វិន័យនេះគឺរួមទាំង ការកុំឲ្យនិយាយទូរស័ព្ទដៃ នៅពេលឆ្លងថ្នល់ ឬនៅពេលដើរលើចិញ្ចើមថ្នល់ ផងដែរ។

ដំណឹងគួរឲ្យចាប់អារម្មណ៍ គឺ ក្នុងចំណោមក្មេងដែលចូលរួមក្នុងការសិក្សាពិសោធន៍នេះ ចំនួន 33% មានទូរស័ព្ទដៃខ្លួនឯង ហើយចំនួន 85% ប្រើទូរស័ព្ទជារៀងរាល់ពេល ទោះបីជាទូរស័ព្ទនោះ ជារបស់ឪពុកម្តាយ ឬជារបស់បងប្អូនខ្លួនក៏ដោយ។  ចំនួន 65% យកទូរស័ព្ទជាប់នឹងខ្លួននៅពេលចេញដើរ, 87% និយាយទូរស័ព្ទអស់រយៈពេលតិចជាង 10 នាទីក្នុងមួយថ្ងៃ។ ឯចំនួន 10% ប្រើទូរស័ព្ទដៃពី 11 នាទី ទៅ 12 នាទី ក្នុងមួយថ្ងៃ។ ហើយ ចំនួន 17% គឺនិយាយទូរស័ព្ទនៅពេលខ្លួនកំពុងដើរ។

ចំពោះពត៌មានបន្ថែម ស្តីអំពីការជៀសវាងគ្រោះថាក់ផ្សេងៗសំរាប់ក្មេង សូមមេត្តាអាន វ៉ិបសៃរបស់កម្មវិធីការពារគ្រោះថ្នាក់សំរាប់ក្មេងទូទាំងពិភពលោក, Safe Kids Worldwide ដែលមានអាសយដ្ឋាន  www.safekids.org ។

Source: http://www.healthfinder.gov/news/newsstory.asp?docid=614459